## Family Resouce Centre
## (មណ្ឌលឯកសារនិងគ្រឿងប្រើប្រាស់សំរាប់គ្រួសារ)

Family Resource Centre គឺជាកន្លែងមិនព្យាបាលរោគរបស់មន្ទីរពេទ្យ ដែលផ្តល់ជូនសំរាប់គ្រួសារនិងអ្នកផ្តល់ការថែទាំអ្នកជម្ងឺទាំងនៅក្នុងនិងទាំងនៅក្រៅមន្ទីរពេទ្យ។ មណ្ឌលនេះផ្តល់កន្លែងស្ងប់ស្ងាត់រាក់ទាក់និងធូរស្រាល សំរាប់គ្រួសារទាំងពួង ក្នុងរង្វង់មន្ទីរពេទ្យ ប៉ុន្តែចេញពីសម្លេងថ្លង់មមាញឹក និង ភាពតានតឹងនៃបរិយាការមន្ទីរពេទ្យ។

មណ្ឌលនេះបានបើកទ្វារឡើងនៅឆ្នាំ 2003 តាមរយៈទឹកចិត្តសប្បុរសធម៌នៃ Bluey Day និង Uncle Bobs Club ដែលជាអ្នកធានាចំបងរបស់យើង។ អ្នកផ្តល់អំណោយជាច្រើនរបស់យើង ត្រូវបានទទួលដឹងឮនៅតាមជញ្ជាំងរាយឈ្មោះអ្នកផ្តល់ជំនួយរបស់យើង នៅក្នុងមណ្ឌលនេះ។

ខ្លឹមសារនិងការផ្តល់គ្រឿងសេវាប្រើប្រាស់នៅក្នុង Family Resource Centre ត្រូវបានជំរុញដោយឪពុកម្តាយ ដោយមានការស្វែងរកមតិជាប់ជានិច្ចពីអ្នកប្រើប្រាស់។ គ្រួសារទាំងពួងត្រូវបានជំរុញទឹកចិត្តឲ្យប្រើគ្រឿងប្រើប្រាស់របស់មណ្ឌលនេះ ដោយមិនពឹងពាក់អ្នកដទៃឡើយ។ យើងស្វាគមន៍ចំពោះការអធិប្បាយនិងមតិឆ្លុះបញ្ចាំងរបស់លោកអ្នក។

ការចាត់ចែងប្រចាំថ្ងៃនៃមណ្ឌលនេះ គឺអាស្រ័យជាខ្លាំងទៅលើអ្នកស្ម័គ្រចិត្ត ហើយយើងសូមថ្លែងអំណរគុណនិងទទួលស្គាល់ការរួមចំណែករបស់អ្នកទាំងនោះចំពោះមណ្ឌលនេះ។

Family Resource Centre មានទំនាក់ទំនងជិតស្និទ្ធ ហើយរួមបញ្ចូលមុខងារឯកសារនិងគ្រឿងប្រើប្រាស់ខ្លះជាមួយនឹង Child Health Information Centre (មណ្ឌលពត៌មានសុខភាពកុមារ), RCH Safety Program (កម្មវិធីសុវត្ថិភាព RCH), Social Work Department (ក្រសួងកិច្ចការសង្គម) និង RCH Education Institute (វិជ្ជាស្ថានអប់រំ RCH)។

## Family Resouce Centre ផ្តល់ -

- កន្លែងទទួលភ្ញៀវមួយដែលធ្វើការដោយអ្នកស្ម័គ្រចិត្តម្នាក់និងបុគ្គលិកធ្វើការម្នាក់ ដើម្បីផ្តល់ការណែនាំ ឯកសារនិងគ្រឿងប្រើប្រាស់  ជំនួយនិងការគាំទ្រ។
- បន្ទប់អង្គុយលេងមួយសំរាប់ឪពុកម្តាយ ដែលមានភាពស្ងប់ស្ងាត់ធំទូលាយនិងសុខស្រួល សំរាប់ការលំហែ  សំរាក និង អាន។
- បន្ទប់ប្រជុំមួយសំរាប់គោលបំណងផ្សេងៗ ដែលអាចបំរុងទុកជាមុនដោយក្រុមគាំទ្រនិងគ្រួសារ ដែលមានបំណងជួបដោយផ្ទាល់ខ្លួនជាមួយនឹងបុគ្គលិកសង្គមកិច្ច ឬ បុគ្គលិកផ្សេងទៀត។
- ការជួបជាមួយបុគ្គលិករបស់ Centrelink (ដោយការណាត់ជួប)។
- បន្ទប់ស្ងប់ស្ងាត់មួយដែលគ្រួសារទាំងពួងអាចជួបជុំគ្នាជាសម្ងាត់ដើម្បីពិភាក្សាអំពីស្ថានភាពរោគរបស់កូនគេ ឬ បញ្ហាគ្រួសារ។
- បន្ទប់ឯកសារនិងគ្រឿងប្រើប្រាស់មួយដែលមានផ្នែកឯកសារយោងទូលំទូលាយ និង វីដេអូសំរាប់ទស្សនា ដោយផ្តល់ពត៌មានអំពីស្ថានភាពរោគទូទៅនិងរោគដ៏កំរ ការចិញ្ចឹមបីបាច់កូន និង ពិការភាព។
- មណ្ឌលអាជីវកម្មមួយសំរាប់គ្រួសារ ដើម្បីប្រើអ៊ីនធើរណិត អ៊ីមែលថតចម្លងឯកសារ ឬ ផ្ញើនិងទទួលទូរសារ (fax) ។
- កន្លែងចង្ក្រានបាយមួយសំរាប់រៀបចំអាហារសម្រន់។ មានផ្តល់ជូនភេសជ្ជៈដូចជាតែនិងកាហ្វេជាដើម។
- កន្លែងអាហារមួយ ដែលផ្តល់តុនិងកៅអី ដោយមានកន្លែងលេងសំរាប់កុមារ នៅជាប់នោះ។
- បន្ទប់តូចៗផ្ទាល់ខ្លួន សំរាប់ឲ្យអ្នកជម្ងឺគេងទម្រេតខ្លួន ឬ ទទួលការផ្តល់អាហារតាមបំពង់បញ្ចូល នៅក្នុងទីកន្លែងសំរាកកាយ។
- កន្លែងខាងក្រៅអាគារមួយ សំរាប់ការគិតគូរបញ្ហាដោយស្ងប់ស្ងាត់។
- ទូចាក់សោដែលមានទំហំផ្សេងៗគ្នា ដើម្បីទុកឥវ៉ាន់មានតម្លៃរបស់លោកអ្នក ក្នុងអម្លុងពេលថ្ងៃ។

## បន្ទប់ថែទាំផ្ទាល់ខ្លួន

បន្ទប់ថែទាំផ្ទាល់ខ្លួន គឺជាផ្នែកនៃ Family Resource Centre ហើយស្ថិតនៅឯកន្លែងទល់មុខគ្នានឹងទ្វារចូលទៅកាន់មណ្ឌលនេះ។ បន្ទប់នេះបានត្រូវរៀបចំឡើងជាពិសេសសំរាប់ក្មេងធំ និង ជនជំទង់ដែលមានជម្ងឺរ៉ាំរ៉ៃ ឬ សេចក្តីត្រូវការពិសេស។ គ្រឿងប្រើប្រាស់ក្នុងបន្ទប់ងូតទឹក, បន្ទប់ផ្លាស់ខោអាវ, គ្រែដែលអាចកែតម្រូវកំពស់ និងបង្គន់ ផ្តល់លទ្ធភាពសំរាប់ឲ្យអ្នកពិការប្រើប្រាស់យ៉ាងងាយស្រួល។

បន្ទប់ថែទាំផ្ទាល់ខ្លួននេះ ក៏នឹងបំពេញតាមតម្រូវការផងដែរនៃជនវ័យក្មេងទាំងនេះ ដែលត្រូវការជំនួយពីឪពុកម្តាយឬអ្នកផ្តល់ការថែទាំរបស់ខ្លួន លើការទៅបង្គន់និងអនាម័យផ្ទាល់ខ្លួន ឬ ទម្រង់ការឯទៀត។

## ទីកន្លែងរបស់យើង

រៀបចំចំណីអាហារសម្រន់ ឬ ពិសារតែកាហ្វេ

បើកមើលឯកសារ ប្រើគ្រឿងប្រើប្រាស់ និង ទទួលពត៌មាន

សូមអញ្ជើញចូល ហើយ រីករាយនឹងពេលសំរាកខ្លះ

Family Resource Centre បើកទ្វារធ្វើការ

ថ្ងៃច័ន្ទ - សុក្រ
9 ព្រឹក - 5 ល្ងាច

ជាន់ទីមួយ អាគារចំបង
(បត់ឆ្វេង នៅខាងក្រោយឱសថស្ថាន)
Royal Children's Hospital (មន្ទីរពេទ្យកុមារ)

Family Resource Centre
Royal's Children Hospital, Flemington Road
Parkville Victoria 3052
ទូរស័ព្ទ: **03 9345 4662** ទូរលេខ: **03 9345 4661**
អ៊ីមែល: frc@rch.org.au អ៊ីនអើរណិត: www.rch.org.au/frc

# Family Resource Centre

(មណ្ឌលឯកសារនិងគ្រឿងប្រើប្រាស់សំរាប់គ្រួសារ)